# ការមានផ្ទៃ និង MPOX

**ខណៈពេលដែលនរណាម្នាក់អាចទទួលបាន mpox អត្រាបញ្ជូន បច្ចុប្បន្នក្នុងចំណោមសាធារណៈជនមានកម្រិតទាប។ អ្នកមានផ្ទៃពោះអាចឈឺខ្លាំងពីជំងឺmpox ដូច្នេះវាសំខាន់ណាស់ក្នុង ការដឹងពីរោគសញ្ញា និងវិធានការការពារ។**

## តើ MPOX គឺជាអ្វី?

Mpox គឺជាជម្ងឺបានបណ្តាលដោយវីរុស mpox។ វារីករាលដាលជាចម្បងតាមរយៈការប៉ះនឹងស្បែក (ការឱប ការថើប សកម្មភាពផ្លូវភេទ) ជាមួយនឹងអ្នកដែលមានជំងឺ mpox។ វាក៏អាចរាលដាលដោយការចែករំលែករបស់របរ (កម្រាលគ្រែ កន្សែង សម្លៀកបំពាក់ ពែង សមស្លាបព្រា) ជាមួយអ្នកណាដែលអ្នកដែលមាន mpox។

## តើរោគសញ្ញា MPOX មានអ្វីខ្លះ?

**អ្នកដែលមាន mpox រួមទាំងអ្នកដែលមានផ្ទៃពោះអាចវិវត្តទៅជារោគ សញ្ញាដូចខាងក្រោម។ រោគសញ្ញាចម្បងគឺជារោគថើស្បែក ដែលអាចមានទ្រង់ទ្រាយដូចជាមុន ឬពង ។ ទាំងនេះអាចលេចឡើងនៅលើមុខ ខាងក្នុងមាត់ និងនៅលើផ្នែក ផ្សេងទៀតនៃរាងកាយដូចជាដៃ ជើង ទ្រូង ប្រដាប់ភេទ និងរន្ធគូថ ។ នុងករណីខ្លះ មនុស្សអាចរីករាលដាល mpox សូម្បីតែមុនពេលពួកគេ បង្កើតរោគសញ្ញាដែលអាចមើលឃើញក៏ដោយ។**

**រោគសញ្ញាដទៃទៀត**

- ប្រព័ន្ធដង្ហើម
- គ្រុនក្តៅ និងរងាញាក
- គ្រុនក្តៅ និង រងាញាក់
- ការហើមកូនកណ្តុរ
- ការឈឺក្បាល
- អស់កម្លាំង

## តើ MPOX អាចប៉ះពាល់ដល់ជនដែលមានផ្ទៃពោះ?

Mpox អាចត្រូវបានបញ្ជូនទៅទារកក្នុងអំឡុងពេលមានផ្ទៃពោះឬទៅទារកទើបនឹងកើតដោយការប៉ះពាល់ជាមួយកន្ទួល mpox ឬដំបៅអំឡុងពេលនិងក្រោយពេលកើត។ Mpox ក្នុងការមានផ្ទៃពោះក៏អាចនាំឱ្យរលូតកូន ទារកកើតលឿនពេក (កើតមិនគ្រប់ខែ) ឬសូម្បីតែគភ៌ស្លាប់មុនពេលសម្រាល។

## តើអ្នកអាចការពារវីករាលដាលនៃ MPOX?

- ជៀសវាងការទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកដែលមាន ឬអាចមាន mpox ឬអ្នកដែលមានកន្ទួល ឬដំបៅដែលមិនអាចពន្យល់បាន។
- សួរដៃគូរួមភេទរបស់អ្នក ឬដៃគូររបស់ពួកគេប្រសិនបើពួកគេមានកន្ទួល ឬដំបៅ ឬរោគសញ្ញា mpox ផ្សេងទៀត ឬមាន/អាចត្រូវបានបង្ហាញ។
- ជៀសវាងចែករំលែករបស់របរប្រើប្រាស់ជាមួយអ្នកណាដែលមាន mpox។ របស់របរត្រូវតែយកសំអាតនឹងសម្លាប់មេរោគ មុននឹងយកមកប្រើដោយអ្នកដទៃ។
- ប្រសិនបើអ្នកមានកន្ទួលសកម្ម ឬរោគសញ្ញាផ្សេងទៀត សូមស្នាក់នៅបន្ទប់ដាច់ដោយឡែក ឬកន្លែងឆ្ងាយពីមនុស្ស ឬសត្វចិញ្ចឹមដែលអ្នករស់នៅ។ ប្រសិនបើអ្នកត្រូវការនៅក្បែរអ្នកដទៃនៅក្នុងផ្ទះរបស់អ្នក (ឧ. ថែទាំកុមារ ឬសមាជិកគ្រួសារ) បិទបាំងដំបៅ/កន្ទួល ហើយពាក់ម៉ាស។

## តើមានវ៉ាក់សាំង ឬការព្យាបាលសម្រាប់ MPOX សម្រាប់បុគ្គល ដែល មានផ្ទៃពោះឬទេ?

**វ៉ាក់សាំង mpox គឺសម្រាប់អ្នកដែលគិតថាខ្លួនឯងមានហានិភ័យ ចំពោះ mpox ហើយអាចជួយការពារការឆ្លងមេរោគ និងកាត់បន្ថយ ជំងឺធ្ងន់ធ្ងរ។ វ៉ាក់សាំងនេះក៏អាចត្រូវបានផ្តល់ឱ្យអ្នកដែលត្រូវបានប៉ះពាល់នឹង mpox ក្នុងរយៈពេល 4-14 ថ្ងៃដំបូងបន្ទាប់ពីការប៉ះពាល់។ មាននូវការព្យាបាលជូនសម្រាប់បុគ្គល ដែលមានរោគសញ្ញា ។**

**ដោយសារតែអ្នកមានផ្ទៃពោះមានហានិភ័យខ្ពស់នៃការឈឺខ្លាំងពី mpox វាជាការសំខាន់ក្នុងការទាក់ទងអ្នកផ្តល់សេវាថែទាំសុខភាព ភ្លាមៗ ប្រសិនបើអ្នកសម្គាល់ឃើញរោគសញ្ញា ឬត្រូវបានប៉ះពាល់។**

GO.CDPH.CA.GOV/MPOX


June 2023 • © 2023, California Department of Public Health